# ធនាគារពិភពលោកៈ កម្ពុជានឹងទទួលបានកំណើនសេដ្ឋកិច្ច៧ភាគរយបីឆ្នាំជាប់គ្នា

**ភ្នំពេញៈ** ធនាគារពិភពលោក កាលពីព្រឹកមិញនេះ បានអះអាងថា កម្ពុជានឹងទទួលបាននូវកំណើនសេដ្ឋ-កិច្ច ៧ ភាគរយ បីឆ្នាំជាប់ៗគ្នា ពីឆ្នាំ ២០១៣ នេះ រហូតដល់ឆ្នាំ២០១៥ ខាងមុខ ។

យោងរបាយការណ៍មួយដែលប្រកាសដោយធនាគារពិភពលោក កាលពីថ្ងៃទី៧ខែតុលានេះបានឱ្យដឹងថា សេដ្ឋ-កិច្ចកម្ពុជា នៅតែមានលក្ខណៈរឹង មាំក្នុងពេលដែលបរិស្ថានពិភពលោកជួបបញ្ហាប្រឈម ហើយភាពក្រីក្របានថយចុះយ៉ាងខ្លាំងប្រមាណជា២០ភាគរយ។

ប្រភពដដែលបានឱ្យដឹងថាបីជាបរិស្ថានសេដ្ឋកិច្ចពិភពលោកជួបបញ្ហាប្រឈម ហើយលទ្ធភាពសម្រេចបាននូវកំណើនដែលបានព្យាករណ៍ថា ស្មើនឹង ៧ ភាគរយ នៅឆ្នាំ២០១៣ នេះ គឺទំនងជាអាចអនុវត្តបាន ។

ប្រភពដដែលបានបន្តទៀតថា កម្ពុជា ជាប្រទេសមួយដែលមានសេដ្ឋ-កិច្ចផ្តោតលើការនាំចេញដោយសារកំណើនផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា គឺដើរដោយកំណើនខ្ពស់នៃវិស័យកសិកម្ម និងការនាំចេញផលិតផលកាត់ដេរ ព្រមទាំងសកម្មភាពសំណង់កំពុងតែមានសន្ទុះ និងកំណើនដ៏រឹងមាំនៃវិស័យទេសចរណ៍។

បើទោះបីជាធនាគារពិភពលោក បានអះអាងអំពីកំណើននៃសេដ្ឋ-កិច្ចប្រកបដោយភាពវិជ្ជមានយ៉ាងណាក៏ដោយ ប៉ុន្តែរបាយការណ៍នេះក៏នៅមិនទាន់បង្ហាញពីភាពជឿជាក់នៅក្នុងការធានានូវបញ្ហាដែលទាក់ទងនឹង ផលប៉ះពាល់ពីការបោះឆ្នោតនៅឡើយ ទេ ។

របាយការណ៍នេះបានបញ្ជាក់ថា "គេមិនដឹងច្បាស់លាស់ថា តើផលប៉ះពាល់នៃភាពមិនច្បាស់លាស់ខាងនយោបាយក្រោយពីការបោះឆ្នោតមកលើការវិនិយោគដោយផ្ទាល់ពីបរទេស និងកំណើនសេដ្ឋកិច្ច មានទំហំប៉ុនណានោះទេ ទោះបីជាមានការប្រសើរឡើងជាងមុនខ្លះចំពោះសេដ្ឋកិច្ចនៅបណ្តាប្រទេសនានាក៏ដោយ" ។

លោក អាឡាសាន សូ ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា បានអះអាងថា កម្ពុជានៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះគឺមានការរីកចម្រើនច្រើន ។

លោកបានបន្តទៀតថា ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺមានលក្ខណៈគួរឱ្យចាប់អារម្មណ៍ជាងគេជាពិសេស គឺការសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រដោយនៅប្រមាណជា ២០ភាគរយ នៅឆ្នាំ២០១១ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋប្រមាណជា៥០ភាគរយនៅតែមានភាពងាយរងគ្រោះទៅនឹងវិបត្តិសេដ្ឋកិច្ចដែលធ្វើឱ្យពួកគេធ្លាក់ចូលក្នុងភាពក្រីក្រសាជាថ្មី ។

លោក លី សួដេត មន្ត្រីជំនាញផ្នែកនៃការកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ច ប្រចាំធនាគារពិភពលោក បានឱ្យដឹងថា វិស័យកសិកម្មគឺជាប្រភពដ៏សំខាន់សម្រាប់ធានាកំណើនដ៏រឹងមាំនេះដោយសារការពង្រីកផ្ទៃដីដាំដុះនិងប្រព័ន្ធស្រោចស្រព ។

លោកបានបន្តទៀតថា ការនាំចេញសម្លៀកបំពាក់ទៅកាន់ទីផ្សារក្រៅប្រទេស គឺនៅតែទទួលការបញ្ជាទិញ ហើយចំនួនកាន់តែច្រើនដូចឆ្នាំ២០១២ កន្លងទៅដែរ ។ ដោយឡែកវិស័យទេសចរណ៍បរទេសចូលទស្សនា ប្រទេសកម្ពុជា នៅឆ្នាំ២០១៣មាន ចំនួនកើនឡើងច្រើនជាងចំនួនទេសចរ ឆ្នាំមុនៗ ។

ជុំវិញបញ្ហាហានិភ័យផ្សេងៗ ធនាគារពិភពលោក បានអះអាងថា អាជ្ញាធរនានានៅកម្ពុជាចាំបាច់ត្រូវតែត្រៀមលក្ខណៈជាស្រេច ដើម្បីឆ្លើយតបទៅនឹងកំណើនជាបន្តបន្ទាប់នៃអត្រាការប្រាក់នៅក្នុងបណ្តាប្រទេសជឿនលឿន និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនទ្វេដង ដើម្បីស្តារឡើងវិញនិងរក្សានូវស្ថិរភាពហិរញ្ញវត្ថុ ។

របាយការណ៍នេះបានបន្តទៀត ថា នៅក្នុងរយៈពេលវែងដោយសារតែអត្រាការប្រាក់ពិភពលោកដែលកើនឡើងកាន់តែខ្ពស់ ទំនងជានឹងប៉ះពាល់ដល់វិនិយោគទុន ការបង្កើនកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ពឹងផ្អែកយ៉ាងសំខាន់លើការកែលម្អកំណែទម្រង់រចនាសម្ព័ន្ធប្រទេសកម្ពុជាក៏ដូចជាប្រទេសនានា ចាំបាច់ត្រូវតែធ្វើឱ្យប្រសើរឡើងដល់បរិយាកាសវិនិយោគរបស់ខ្លួន និងការវិនិយោគបន្ថែមទៀត លើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ក្នុងខណៈដែលកំពុងតែធ្វើឱ្យវិនិយោគទុនសាធារណៈកាន់តែមានប្រសិទ្ធភាព។

ប្រភពដដែលបានបន្តទៀតថា ទស្សនៈវិស័យនៃកំណើនសេដ្ឋកិច្ចពិភពលោកដែលកាន់តែរឹងមាំអាចជួយដល់បណ្តាប្រទេសកំពុងអភិវឌ្ឍឱ្យបន្តធ្វើកំណែទម្រង់នានាដោយធ្វើឱ្យប្រទេសមានលទ្ធភាពអាចទទួលបាននូវអត្ថប្រយោជន៍ពីការងើបឡើងវិញ

តទៅទំព័រ ក4

តមកពីទំព័រ ក3

## ធនាគារពិភពលោក...

នៃសេដ្ឋកិច្ច និងរក្សាបាននូវកំណើន របស់ខ្លួនកាន់តែរឹងមាំ ។

ប្រភពដដែលបានបន្តទៀតថា សម្រាប់ហានិភ័យនានា ប្រទេសកម្ពុជា និងប្រទេសមួយចំនួនគឺចាំបាច់ត្រូវតែ ឆ្លើយតបទៅនឹងហានិភ័យនៃសារពើពន្ធ និងបង្កើតនូវឱកាសដើម្បីគាំទ្រ ដល់កំណើនរយៈពេលវែងជាមួយនឹង វិធានការនានារួមបញ្ចូលទាំងការកាត់ បន្ថយប្រាក់ឧបត្ថម្ភលើថាមពល ។

លោក ហូហ្វមេន បានឱ្យដឹងថា កំណែទម្រង់រចនាសម្ព័ន្ធដែលនឹងផ្តល់ នូវការលានុវត្តភាពសម្រាប់ប្រជាពល-រដ្ឋក្នុងការចែក រំលែក ផលចំណេញ ពីភាពរីកចម្រើន គឺជាគន្លឹះឆ្ពោះទៅរក កំណើននាពេលអនាគត ។

គួររំលឹកដែរថា នៅក្នុងឆ្នាំ ២០១៣ នេះ ធនាគារនេះបានព្យាករណ៍ ថា ប្រទេសឥណ្ឌូណេស៊ីនឹងទទួលបាន កំណើនសេដ្ឋកិច្ចនេះប្រមាណជា៥,៦ ភាគរយ ម៉ាឡេស៊ី ចំនួន៤,៣ ភាគរយ ហ្វីលីពីន ៧ ភាគរយដែរ ថៃ ៤ ភាគ-រយ វៀតណាម ៥,៣ ភាគរយ ឡាវ ៨ ភាគរយ និង ភូមាចំនួន ៦,៨ ភាគរយ៕

**ពិស្ណារ**